# សិលាចារឹកមិនស្គាល់ប្រភព K.៧៩០

## ១- ព័ត៌មានទូទៅ

សិលាចារឹកមួយផ្ទាំងនេះ មិនស្គាល់ប្រភពច្បាស់លាស់ឡើយ។ តាមលោក ហ្សឺក សេដែស បញ្ជាក់ថាវាជាសមុច្ច័យរបស់លោក ឡូប៉េហ្ស (Lopez) ដែលបានក្លាយជាឧកញ៉ាយោមរាជ គឺរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៃរដ្ឋាភិបាលប្រទេសកម្ពុជា អំឡុងខែធ្នូ ឆ្នាំ១៩៥២[១]។ តាមរយៈរបាយការណ៍បានបញ្ជាក់ឱ្យដឹងថា ផ្ទាំងចារឹកនេះ យកចូលមកកាន់សារមន្ទីរជាតិ តាំងពីថ្ងៃទី១៦ កុម្ភៈ ឆ្នាំ១៩៣៩ មកម្ល៉េះ។ នៅក្នុងឆ្នាំ១៩៦៩ បានដឹកយកទៅរក្សាទុកនៅអភិរក្សអង្គរ បន្ទាប់មកនៅឆ្នាំ១៩៩៣ បានដឹកមករក្សាទុកនៅព្រះបរមរាជវាំង និងចុងក្រោយនៅឆ្នាំ២០០៦ ដឹកយកមករក្សាទុកជាថ្មីម្តងទៀតនៅសារមន្ទីរជាតិភ្នំពេញរហូតមកដល់ពេលបច្ចុប្បន្ន[២]។

សិលាចារឹកនេះ សាងអំពីថ្មស្រទាប់ ឬថ្មធ្នូ មានកម្ពស់៧០ស.ម. បន្ទារ២៩ស.ម. និងកម្រាស់៥ស.ម.។ តាមរយៈសម្ភារៈ លក្ខណៈចារ និងតួអក្សរ សិលាចារឹកមួយផ្ទាំងនេះ គួរតែមានប្រភពចេញពីតំបន់ណាមួយនៃរាជធានីភ្នំពេញ ខេត្តកណ្តាល ព្រៃវែង កំពង់ស្ពឺ ឬខេត្តតាកែវ។ នៅលើផ្ទាំងចារឹកនេះ មានធ្លាក់ក្បាច់ផ្កាខាងលើ មានក្បាច់ពងត្រីរាយជាខ្សែផ្តេកនៅខាងក្រោម និងមានអត្ថបទចារឹកចំនួន១៨បន្ទាត់ មានសភាពលក្ខណៈល្អ លើកលែងតែនៅបន្ទាត់ចុងក្រោយ ដាច់បាត់អក្សរមួយចំនួន។

តើសិលាចារឹកនេះ ចារនៅឆ្នាំណា? មានអត្ថន័យដូចម្តេច?

សិលាចារឹកនេះ ពុំមានចុះកាលបរិច្ឆេទឡើយ ប៉ុន្តែតាមលក្ខណៈបុរាណលេខន៍សាស្ត្រ (Paleography) អាចកំណត់បានថាមានកាលបរិច្ឆេទអំឡុងស.វ.ទី៧ នៃគ្រិស្តសករាជ។ អត្ថន័យនៃសិលាចារឹកនេះ គឺជាបញ្ជីតង្វាយរបស់បោញ សិង ជាម្ចាស់ដើម

---

[១] ហ្សឺក សេដែស ១៩៥៣។

[២] របាយការណ៍ពេងដាងជួសជុលថ្មនៃសារមន្ទីរជាតិនិងសាលាបារាំងចុងបូព៌ាប្រទេស។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

បុណ្យបានថ្វាយខ្ញុំបម្រើប្រុសចំនួន៦នាក់ ខ្ញុំបម្រើស្រីចំនួន៦នាក់ និងដីស្រែ១០កន្លែង និងដើមដូងផង ចំពោះប្រាសាទដែលពុំស្គាល់ឈ្មោះ។

## ២- អត្ថបទដើមជាអក្សរខ្មែរទំនើប

១- អំនោយ៑បោញ៑សិង៑យជមានអាយ៑ត

២- ក្បោញ៑កម្រតាង៑អញ៑ក្ញុំតសិយ៑វា

៣- សល្មុហាន៑១វាត្នាន៑១(វាក្វង៑នោង៑)១វាច

៤- បោត៑១វាបរោយ៑១វាក្រហោង៑១ក្ញុំតក

៥- កន្ទែកុថ្ងៅ១កុចិត្តអវៃ១កុស្មង៑១កុ

៦- ស្កាញ៑១កុកញ្ចុស៑១កុកល្បិត៑១ស្រេអា

៧- យ៑អាវាសបាទកាច៑មោយ៑សទ្រេ

៨- យ្យស្រេអាយ៑តំរិនៅត្នោង៑៣ស្រេអា

៩- យ៑ត្នល៑វិហារ៑ត្នោង៑២ស្រេអាយ៑ស្តុក៑

១០- លោច៑ត្នោង៑៧ស្រេអាយ៑ស្តុក៑ស្តះផោង៑

១១- ត្នោង៑៧ស្រេមន៑បោញ៑កំរៅសំវ្យវហារ

១២- ទោង៑បោញ៑អក្សរគុប្បខត្តរីយ

១៣- បោញ៑កំរៅបញ្ចៅគុ◌៑តបោញ៑យជ

១៤- មានសិង៑ត្នោង៑១ស្រេអាយ៑វ្រហ្មរ៑

១៥- បាទកាច៑មោយ៑សទ្រេយស្រេមេ

១៦- ហោង៑អញ៑ត្នោង៑១ស្រេតំវ្រេង៑ត្នោង៑១

១៧- --=ស្រេតំសង្កេត្នោង៑១ជេ=សវ៌បិណ្ឌ

១៨- ------◌ោង៑----តោង៑ត្នំ--

## ៣- អត្ថបទប្រែសម្រួល

តង្វាយរបស់បោញសិងជាម្ចាស់ដើមបុណ្យថ្វាយចំពោះក្បោញគម្តែងអញ។ អ្នកបម្រើប្រុស(មាន៖) វាសល្មុហាន១ វាត្នាន១ (វាក្វងនោង)១ វាចបោត១ វាបរោយ១ វាក្រ

អត្ថបទដោយៈ ហ៊ុន ឈុនតេង

ហោង១។ អ្នកបម្រើស្រី(មានៈ)កុថ្ងៅ១ កុចិត្តអវែ១ កុស្មង១ កុស្ពាញ១ កុកញុស១ កុកល្បិត១។ ស្រែនៅឯអាវាស ១សទ្រែថៃមក្បាច់១បាទ, ស្រែឯដើមធ្នោ៣ត្លោង, ស្រែឯថ្នល់វិហារ ២ត្លោង, ស្រែឯស្តុកលោច៧ត្លោង, ស្រែឯស្តុកស្តះ៧ត្លោង, ស្រែដែលបោញកំរៅមានក្តីក្តាំជាមួយបោញអក្សរគុប្ប ហើយបានឈ្នះនោះ បោញកំរៅបានលក់ឱ្យដល់បោញសិង ជាម្ចាស់ដើមបុណ្យចំនួន១ត្លោង, ស្រែឯព្រហ្មរី ១សទ្រែថៃមក្បាច់១បាទ, ស្រែមេហោងអញ ១ត្លោង, ស្រែដើមព្រីង១ត្លោង, ----២(ដើ), ស្រែដើមសង្កែ១ត្លោង ២ដើ។ សរុបរួម ---- ដូង-ដើម។

## កំណត់ពន្យល់ពាក្យ

គួរបញ្ជាក់ផងដែរថា ពាក្យ «វា» ជាពាក្យសម្គាល់អ្នកបម្រើភេទប្រុស។ ពាក្យនេះក្លាយមកជាសព្វនាម «វា» និង «វ៉ា» ក្នុងពាក្យ «អាវ៉ា»។ ពាក្យ «សិ/សី/សិយ៉» ជាពាក្យសម្គាល់មនុស្សប្រុសទូទៅ ដែលបច្ចុប្បន្ននៅសល់ក្នុងពាក្យ «ប្តីសី»។ ឯពាក្យ «កុ» ជាពាក្យសម្គាល់អ្នកបម្រើភេទស្រី។ ពាក្យ «កន្ត្តែ» ជាពាក្យសម្គាល់មនុស្សស្រីទូទៅ។

ពាក្យ «សទ្រែ» ជាខ្នាតស្រែ។ ឯ «ត្លោង» «ដេ» ច្រើនតែប្រើជាខ្នាតវង្វាល់ធញ្ញជាតិ ដែលនៅក្នុងទីនេះ សម្គាល់ទំហំខ្នាតស្រែតាមវង្វាល់គ្រាប់ពូជសម្រាប់ព្រោះ(?)។

ពាក្យ «កាចិ» ត្រូវនឹងពាក្យបច្ចុប្បន្នថា «កាច់»។ ពាក្យនេះប្រើក្នុងន័យដូចនឹងពាក្យ «ក្បាច់» ដែរ គឺសំដៅដល់ចំនួនថៃមតែគេកាច់យកបន្ថែមពីចំនួនដែលគេសន្មតកំណត់យកណាមួយ។

## បញ្ជីឯកសារ

Cœdès, George. (1953). Stele de la collection de Lopez (Phnoṃ Peñ). In *Inscription du Cambodge* (Vol. V, pp. 71-72). Paris: Editions de Boccard.

រោងជាងជួសជុលថ្មនៃសារមន្ទីរជាតិ និង សាលាបារាំងចុងបូព៌ាប្រទេស. របាយការណ៍សិលាចារឹក ក.៣០៦៣ (K.៧៩០)

អត្ថបទដោយៈ ហ៊ុន ឈុនតេង

# បញ្ជីរូបភាព



សំណៅផ្តិតសិលាចារឹក K.៧៩០ (រូបថត៖ EFEO_CAM17126_bis2)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



សំណៅចម្លងសិលាចារឹក K.៧៩០ (ចម្លងដោយៈ ហ៊ិន ឈុនតេង)

អត្ថបទដោយៈ ហ៊ិន ឈុនតេង